**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**គណៈកម្មការប្រឡងជ្រើសរើស**
**និស្សិតចូលរៀនថ្នាក់វេជ្ជបណ្ឌិតឯកទេស**
**នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល**

ថ្ងៃសុក្រ ១១ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែតុលា ឆ្នាំ២០២២

# បទបញ្ជាផ្ទៃក្នុង

## សម្រាប់ការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់វេជ្ជបណ្ឌិតឯកទេស នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

ដើម្បីធានាឱ្យការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់វេជ្ជបណ្ឌិតឯកទេស នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ប្រព្រឹត្តទៅដោយភាពត្រឹមត្រូវ យុត្តិធម៌ សមភាព និងតម្លាភាព បេក្ខជនទាំងអស់ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រឡងដែលមានចែងដូចខាងក្រោម ៖

១- បេក្ខជនត្រូវគោរពតាមកាលវិភាគប្រឡងដែលបានកំណត់និងផ្សព្វផ្សាយដោយគណៈកម្មការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់វេជ្ជបណ្ឌិតឯកទេសនៅស.វ.ស ។

២- បេក្ខជនត្រូវមកមណ្ឌលប្រឡង<u>មួយម៉ោងកន្លះ (៩០នាទី) មុន</u>ពេលចូលបណ្តុះបណ្តាល និងមុនពេលប្រឡងតាមវេននីមួយៗ និងត្រូវឆ្លងកាត់ការធ្វើតេស្តរហ័សរកមេរោគកូវីដ-១៩ មុនពេល បណ្តុះបណ្តាល និងមុនពេល ចូលប្រឡង ។

៣- បេក្ខជនដែលមក<u>**យឺតលើសពី១៥នាទី**</u> ក្រោយពេលការប្រឡងចាប់ផ្តើម នឹងមិនត្រូវបានអនុញ្ញាតអោយចូលប្រឡងឡើយ ហើយត្រូវបានចាត់ទុកថា<u>**អវត្តមាន**</u> និងមិនអនុញ្ញាតអោយប្រឡងជាមួយក្រុមផ្សេងទៀតឡើយ។

៤- បេក្ខជនដែល<u>**អវត្តមាន**</u>ក្នុងពេលប្រឡង នឹងត្រូវបានចាត់ទុកថា<u>**ធ្លាក់ជាស្វ័យប្រវត្តិ**</u>។

៥- ហាមយកអាវុធ ឬជាតិផ្ទុះចូលក្នុងបរិវេណមណ្ឌលប្រឡង។

៦- បេក្ខជនត្រូវមានអាកប្បកិរិយាសមរម្យ និងសម្លៀកបំពាក់និស្សិតក្នុងពេលប្រឡង។

៧- បេក្ខជនត្រូវយកមកជាមួយនូវ បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង ដើម្បីបង្ហាញដល់អនុរក្ស មុនពេលចូលប្រឡង។ ក្នុងករណីគ្មានបង្កាន់ដៃនោះទេ បេក្ខជនត្រូវសុំការបញ្ជាក់ និងការអនុញ្ញាតពីអនុគណកម្មការកណ្តាលជាមុនសិន ។

៨- បេក្ខជនមិនត្រូវបានអនុញ្ញាតិឱ្យយក ប៊ិច ក្រដាស់ សំណៅឯកសារ ទូរស័ព្ទដៃ ឬឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ ចូលក្នុងបន្ទប់ប្រឡងជាដាច់ខាត។ គណៈកម្មការប្រឡង មិនទទួលខុសត្រូវលើការបាត់បង់សម្ភារៈនានារបស់បេក្ខជនឡើយ។ ប្រសិនបើអនុរក្សរកឃើញថាមានសម្ភារៈទាំងនោះជាប់ខ្លួនក្នុងពេលប្រឡង ត្រូវចាត់ទុកថា**ធ្លាក់ដោយស្វ័យប្រវត្តិ**។

៩- ការហៅឈ្មោះចូលបន្ទប់ប្រឡង និងផ្ទៀងផ្ទាត់អត្តសញ្ញាណបេក្ខជននឹងត្រូវធ្វើឡើង**៤០នាទី មុន**ម៉ោងកំណត់ការប្រឡងតាមក្រុមនីមួយៗ។

១០- បេក្ខជនត្រូវតម្រង់ជួរចូលក្នុងបន្ទប់ប្រឡងតាមការហៅឈ្មោះពីអនុរក្ស ដោយឆ្លងកាត់ការត្រួតពិនិត្យ និងស្កេនម្រាមដៃដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់បេក្ខជន ។

១១- បេក្ខជនត្រូវចាប់ឆ្នោតយកលេខកុំព្យូទ័រ ហើយត្រូវចូលទៅកាន់ទីកន្លែងប្រឡងតាមលេខកុំព្យូទ័ររៀងៗខ្លួនតាមការណែនាំរបស់អនុរក្ស ។ បេក្ខជនមិនត្រូវអង្គុយប្រឡងខុសទីតាំងលេខកុំព្យូទ័រដែលចាប់ឆ្នោតបានឡើយ លើកលែងករណីមានបញ្ហាបច្ចេកទេសកុំព្យូទ័រ ទើបគណៈកម្មការកណ្តាលពិនិត្យ និងអនុញ្ញាតឱ្យផ្លាស់ប្តូរកុំព្យូទ័រ ។

១២- បេក្ខជនត្រូវរក្សាសណ្តាប់ធ្នាប់ល្អ និងការស្ងៀមស្ងាត់ក្នុងពេលប្រឡង។ ក្នុងករណីមានបញ្ហាកុំព្យូទ័រ ឬមានបញ្ហាផ្សេងៗទៀតត្រូវលើកដៃជាសញ្ញាប្រាប់ដល់ក្រុមអនុរក្សដើម្បីសុំអន្តរាគមន៍។

១៣- បេក្ខជនណាដែលសាកសួរគ្នាទៅវិញទៅមក ឬ ផ្តល់ឯកសារឱ្យគ្នាក្នុងពេលប្រឡង ឬធ្វើជាសញ្ញាជាកាយវិការផ្សេងៗ បេក្ខជននោះ (ទាំងអ្នកផ្តល់ឯកសារ និងអ្នកទទួលឯកសារ ទាំងអ្នកសួរ និងអ្នកប្រាប់ ទាំងអ្នកផ្តល់សញ្ញា និងអ្នកទទួលសញ្ញា) នឹងត្រូវបញ្ឈប់ពីការប្រឡង និងត្រូវធ្លាក់ដោយស្វ័យប្រវត្តិ ។

១៤- ប្រសិនបើគណៈកម្មការរកឃើញថា មានបេក្ខជនណាមួយត្រូវបានអ្នកផ្សេងមកប្រឡងជំនួស ឬមកប្រឡងជំនួសឱ្យ បេក្ខជនណាម្នាក់ផ្សេង ឈ្មោះបេក្ខជនដែលគេមកប្រឡងជំនួស នោះនឹងត្រូវចាត់ទុកថា**ធ្លាក់ដោយស្វ័យប្រវត្តិ** ។

- បើបេក្ខជន និងជនដែលមកប្រឡងជំនួស ជានិស្សិតកំពុងសិក្សានៅស.វ.ស បេក្ខជនទាំងនោះនឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតដែលខ្លួនកំពុងរៀនបច្ចុប្បន្ន និងត្រូវទទួលទោសតាមច្បាប់ជាធរមាន។
- ចំពោះបេក្ខជន និងជនដែលមកប្រឡងជំនួស មិនមែនជានិស្សិតកំពុងសិក្សានៅស.វ.ស បេក្ខជនទាំងនោះនឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

១៥- ករណីដែលបេក្ខជនប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងចំណុច ១៣ និង១៤ ខាងលើ បេក្ខជនទាំងនោះត្រូវទទួលការពិន័យដោយមិនអនុញ្ញាតឱ្យប្រឡងចូលរៀនថ្នាក់ឯកទេសនៅស.វ.ស ចំនួន០២ឆ្នាំជាប់ៗគ្នា។

**គណៈកម្មការរៀបចំការប្រឡង**
**ប្រធាន**

សាស្ត្រាចារ្យ **ឆា ត្រុយ**